ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ព្រៃកក្របៅ
# រយៈពេល៣ឆ្នាំ( កក្កដា ២០១៩- មិថុនា ២០២២ )

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ព្រៃកក្របៅ |
| ភូមិ | ៖ | ឧត្តម ឧត្តុង្គ និងព្រៃកក្របៅ |
| ឃុំ | ៖ | ព្រៃកក្របៅ |
| ស្រុក | ៖ | ពាមជរ |
| ខេត្ត | ៖ | ព្រៃវែង |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ព្រែកក្របៅ រយៈពេល៣ឆ្នាំ( កក្កដា ២០១៩-មិថុនា ២០២២ )

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ ព្រែកក្របៅ |
| ភូមិ | ៖ ឧត្តម ឧត្តុង្គ និងព្រែកក្របៅ |
| ឃុំ | ៖ ព្រែកក្របៅ |
| ស្រុក | ៖ ពាមជរ |
| ខេត្ត | ៖ ព្រៃវែង |

រៀបចំដោយរដ្ឋបាលជលផល

សហការជាមួយខណ្ឌរដ្ឋបាលជលផលព្រៃវែង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍ ព្រៃកក្របៅ
## រយៈពេល៣ឆ្នាំ(កក្កដា ២០១៩-មិថុនា ២០២២)

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ ព្រៃកក្របៅ |
| ភូមិ | ៖ ឧត្តម ឧត្តុង្គ និងព្រៃកក្របៅ |
| ឃុំ | ៖ ព្រៃកក្របៅ |
| ស្រុក | ៖ ពាមជរ |
| ខេត្ត | ៖ ព្រៃវែង |

រៀបចំដោយរដ្ឋបាលជលផល

សហការជាមួយខណ្ឌរដ្ឋបាលជលផលព្រៃវែង

# មាតិកា
# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១- ស្ថានភាពទូទៅ** ........ ១

**២- អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម** ........ ១

ក- ប្រជាសាស្ត្រ ........ ១

ខ- មុខរបរ ........ ២

**៣- កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........ ២

ក- ទីតាំង ........ ២

ខ- ដែននេសាទ ........ ២

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស ........ ៣

ឃ- ធនធានជលផល ........ ៣

**៤- ការធ្វើនេសាទ** ........ ៣

ក- អ្នកនេសាទ ........ ៣

ខ- ឧបករណ៍នេសាទ ........ ៣

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ ........ ៥

**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ** ........ ៥

ក- ទស្សនៈវិស័យ ........ ៥

ខ- គោលបំណង ........ ៥

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ៦

គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ ៦

គ២- ផែនការកែលម្អកន្លែងនេសាទសហគមន៍ ........ ៧

គ៣- ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស ........ ៨

គ៤- ផែនការគ្រប់គ្រងព្រៃលិចទឹក ........ ៨

គ៥- ផែនការទប់ស្កាត់បទល្មើសជលផល ........ ៩

គ៦- ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ ........ ១០

គ៧- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល ........ ១០

គ៨- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ ........ ១២

គ៩- ផែនការបង្កើតសហគមន៍នេសាទទេសចរណ៍ធម្មជាតិ ........ ១៣

គ១០- ផែនការបង្កើតក្រុមឥណទាន(សន្សំប្រាក់) ដើម្បីបង្កើនមុខរបរ ........ ១៤

គ១១- ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ ........ ១៤

គ១២- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ ........ ១៤

គ១៣- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........ ១៥

ឃ. ផែនការយុទ្ធសាស្ត្រ ........ ១៦

តារាងកម្មវិធីការងារ ........ ១៧

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទព្រែកក្របៅ បានធ្វើមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០។

សហគមន៍នេសាទព្រែកក្របៅ មានទីតាំងស្ថិតនៅភូមិឧត្ដម ឧត្តុង្គ និងភូមិព្រែកក្របៅ ឃុំព្រែកក្របៅ ស្រុកពាមជរ ខេត្តព្រៃវែង។ ដែលមានសមាជិកសហគមន៍នេសាទសរុបចំនួន៧៣០នាក់ ប្រុស៤២១នាក់ ស្រី៣០៩នាក់ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន១៤៦គ្រួសារ។ មានគណៈកម្មការចំនួន០៧នាក់ ស្រីគ្មាន ។

កន្លងមកសហគមន៍នេសាទនេះ បានដំណើរការសកម្មភាពសំខាន់ៗ របស់ខ្លួនរួមមាន ៖

- បោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- រៀបចំបញ្ជីឈ្មោះសមាជិក និងគណៈកម្មការសហគមន៍នេសាទ
- រៀបចំរចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ
- រៀបចំលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- កំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍និងធ្វើផែនទី
- ចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ផ្សព្វផ្សាយច្បាប់ស្ដីពីជលផល
- ទប់ស្កាត់បទល្មើសនេសាទក្នុងកន្លែងនេសាទសហគមន៍
- ចូលរួមរៀបចំបណ្ដាញសហគមន៍នេសាទថ្នាក់ស្រុក និងថ្នាក់ខេត្ត
- ចូលរួមប្រជុំជាមួយភូមិ ឃុំ ស្រុក និងស្ថាប័នពាក់ព័ន្ធ
- បង្កើតក្រុមមុខរបរ (ចិញ្ចឹមសត្វ ដាំបន្លែ ក្រុមសន្សំឥណទាន)
- ប្រមូលព័ត៌មានទូទៅសំរាប់ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

## ២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាសាស្ត្រ

ចំនួនប្រជាពលរដ្ឋសរុបក្នុងតំបន់សហគមន៍មាន៥.២២៤នាក់ ប្រុស២.៦១០នាក់ ស្រី២.៦១៧ នាក់ក្នុងនោះមានចំនួន១.១៩៦គ្រួសារ ។ ប្រជាពលរដ្ឋក្នុងតំបន់ជាអ្នកកាន់សាសនាព្រះពុទ្ធ១០០%។

ក្នុងចំណោមសមាជិកសមាជិកគ្រួសារនៃសហគមន៍នេសាទទាំងអស់ អ្នកមិនចេះអក្សរចំនួន១៨ ស្រី ១៣នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន៥៤២ ស្រី១៩៩នាក់ កម្រិតមធ្យមសិក្សាចំនួន១៥៧នាក់ ស្រី១១០នាក់ និងកម្រិតឧត្តមសិក្សាគ្មាន ។

ប្រជាពលរដ្ឋសរុបក្នុងតំបន់សហគមន៍មានស្ថានភាពដូចខាងក្រោម៖

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍មាន១៤៩នាក់
- ចំនួនជនពិការក្នុងសហគមន៍មាន៣៥នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍មាន២៣នាក់ ស្រី១៥នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍មាន១៧នាក់ ស្រី៩នាក់។

ខ. មុខរបរ

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍ រួមមាន៖

- ធ្វើនេសាទចំនួន៦១៧នាក់ ស្មើនឹង១២៣គ្រួសារ
- ធ្វើស្រែចំនួន១៤៦គ្រួសារ ទំហំ០,៣-១,៥ ហិកតា
- ធ្វើចំការចំនួន១៤៦គ្រួសារ ទំហំ ០,២-១ ហិកតា
- ដាំបន្លែចំនួនចំនួន៣១គ្រួសារ ទំហំ០,១-០,៣ ហិកតា
- ធ្វើវារីវប្បកម្មចំនួនគ្មាន
- ជាងផ្ទះចំនួន១៦គ្រួសារ
- លក់ដូរចំនួន៦៥គ្រួសារ
- កម្មករចំនួន៣២គ្រួសារ
- មន្ត្រីរាជការចំនួន២៥គ្រួសារ
- ចិញ្ចឹមសត្វចំនួន៨គ្រួសារ (ជ្រូក មាន់ ទា គោ)
- ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ១១.៦៨០.០០០ រៀល ។

## ៣ កន្លែងនេសាទសហគមន៍និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

ក. ទីតាំង

កន្លែងនេសាទសហគមន៍ព្រៃកក្របៅ ត្រូវលុបចេញពីអតីតឡូត៍នេសាទលេខ៨ និង១២ នៃដែននេសាទទឹកសាប ក្នុងខេត្តព្រៃវែង មានទំហំ ១.០៦៩ ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងឃុំអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង
- ខាងត្បូងទល់នឹងកន្លែងនេសាទសហគមន៍ស្វាយភ្លោះ និងឃុំស្វាយភ្លោះ ស្រុកពាមជរ ខេត្តព្រៃវែង
- ខាងកើតទល់នឹងឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង
- ខាងលិចទល់នឹងភូមិព្រៃកក្របៅ ឧត្តុង្គ និងភូមិឧត្តម ឃុំព្រៃកក្របៅ ស្រុកពាមជរ ខេត្តព្រៃវែង។

ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ព្រៃកក្របៅ មានបឹងចំនួន២បឹង ព្រែកចំនួន៣ព្រែក អូរចំនួន២អូរ ប្រឡាយចំនួន ២ប្រឡាយ កន្លែងអភិរក្សជលផលចំនួន១ និងដីទំនាបលិចទឹកគឺ៖

| | | |
|---|---|---|
| បឹងដងរ៉ក | ទំហំ ១៣,២ ហិកតា | ពេញមួយឆ្នាំ |
| បឹងបាក់បែង | ទំហំ ១០ ហិកតា | ពេញមួយឆ្នាំ |
| ព្រែកកួយ៉ាវ | ទំហំ ២០ម x ១.៧០០ម | ពេញមួយឆ្នាំ |
| ព្រែកអាមួយ | ទំហំ ៤០ម x ១.៧០០ម | ខែ៦-ខែ១២ |
| ព្រែកអាហ្សូរ | ទំហំ ៦០ម x ១.៨០០ម | ពេញមួយឆ្នាំ |
| អូរ...... | ទំហំ ......ម x.........ម | ពេញមួយឆ្នាំ |
| អូរ...... | ទំហំ ......ម x.........ម | ពេញមួយឆ្នាំ |
| ប្រឡាយជីកថ្មី | ទំហំ ១៥ម x ២.០០០ម | ពេញមួយឆ្នាំ (ទឹកសម្រាប់ធ្វើស្រែប្រាំង) |
| ប្រឡាយភូមិឧត្តម | ទំហំ ២០ម x ១.៧០០ម | ពេញមួយឆ្នាំ (ចំណុចព្រែកកួយ៉ាវ) |

ដីទំនាបលិចទឹកមានទំហំសរុប .................. ហិកតា។

**គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស**

- បឹងដងរ៉ក ទំហំ ១៣,២ ហិកតា ពេញមួយឆ្នាំ
- បឹងបាក់បែង ទំហំ ១០ ហិកតា ពេញមួយឆ្នាំ។

**ឃ. ធនធានជលផល**

- **ប្រភេទត្រី ៖**

ត្រីរ៉ស់ ត្រីប្រា ត្រីឆ្តោរ ត្រីឆ្លាំង ត្រីកែស ត្រីក្អែក ត្រីកញ្ចុះ ត្រីលិញ ត្រីរៀល ត្រីក្រាញ់ ត្រីចង្វារ ត្រីផ្ទោង ត្រីស្លួញ ត្រីពោ ត្រីអាចម៍កុក ត្រីស្លឹកឫស្សី ត្រីកន្ធ្រប់ ក្លាំងហាយ ត្រីខ្នាន់ ត្រីក្រឡង់ ត្រីសណ្តាយ ត្រីអណ្តែង ត្រីដំរី ត្រីតាអោន ត្រីក្រម៉ម ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្ចឹង ត្រីអំពិលទុំ ត្រីគ្រុំ ត្រីផ្កាស្មៅ ត្រីឈ្មៀត ត្រីកញ្ជ្រូក ត្រីបណ្តូលអំពៅ ត្រីប្រកែង ត្រីកាហែ ត្រីក្រឹម ត្រីក្រឹមទន្សាយ ត្រីស្រកាក្តាម ត្រីលលកសរ ត្រីឆ្ពិន ត្រីបណ្តូលចេក ត្រីព្រលូង ត្រីកំពត ត្រីក្រពាត់ ត្រីក្រុស ត្រីកញ្ចាញ់ច្រាស ត្រីកំភ្លាញ ត្រីស្លាត ត្រីក្រាយ ត្រីអណ្តាតឆ្កែ ត្រីកញ្ចនដៃ កំពិស បង្កង។

- **ប្រភេទវារីសត្វ ៖**

អណ្តើក ពស់ ខ្យងគូចស្រួច ខ្យងគូចទាល ខ្យងមាស(ខ្យងពណ៌លឿង) ក្តាម អន្ទង់ ខ្ចៅគូចស្រួច ខ្ចៅគូចទាល កង្កែប ឈ្លើង គ្រុំ គ្រុំចំពុះទា លៀស ។ល។

- **ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ៖**

ដើមថ្លើមអណ្តើក ខ្លបយក្ស(អួយយ៉ាស់/បន្លាយយួន) រាំង ប្របួយមេ ប្របួយឈ្មោល ស្បាត ភ្នំភ្លើង អញ្ចាញ ត្នួ ស្លែងក្របី ធ្មេញត្រីញី ទៀនព្រៃ ត្រស់ ថ្នាង ខ្នាយមាន់ វល្លិ៍ប្រេង វល្លិ៍ទឹកដោះ វល្លិ៍ត្រដិត វល្លិ៍ដោះគន់ វល្លិ៍ត្រី វល្លិ៍ត្អើក អំពាក់ទឹក ស្លាបទា កន្ទាំងហែ ស្នោ ស្លត បន្លាឃ្លេ ថ្ងាន់ ស្លុលទឹក ប្រកែង ប្រធេញ ផ្តៅ ក្អែកព្រាប វល្លិ៍អណ្តាតត្រកួត ក្រចាប់ សារាយសាប កំប្លោក ចកតូច ចកធំ កំពីងពួយស កំពីងពួយក្រហម ត្រកួន ព្រលិតអាចម៍មាន់ ព្រលិតដូង រំចង់ ស្តន់អំបោះ ត្រាវអណ្តែត ស្មៅអន្ទក់ទឹក ស្មៅអំពៅខៀប ចំបូង កក់ជ្រុង កក់ក្តាម ឈូក ចន្ទល់ភ្នំ(វល្លិ៍ថ្គាល់ត្រី) កញ្ឆែត ស្មៅថ្នក់ទឹក ។ល។

## ៤. ការធ្វើនេសាទ

**ក. អ្នកនេសាទ ៖**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៤៩៧នាក់ ស្រី១៦១នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន១២០នាក់ ស្រី៦១នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៨៥នាក់ ស្រី២៦នាក់។

**ខ. ឧបករណ៍នេសាទ ៖**

- ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ...ដល់ខែ...) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ២៩៥ | ១០០-៥០០ម/គ្រួសារ | ៨៨.៥០០ម៉ែត្រ | ពេញរដូវនេសាទ |
| លបឫស្សី | គ្រឿង | ១៣ | ៨គ្រឿង/គ្រួសារ | ១០៤គ្រឿង | ខែសីហា ដល់ ខែវិច្ឆិកា |

| | | | | | |
|---|---|---|---|---|---|
| សំណាញ់ | វង់ | ៩៦ | ១វង់/គ្រួសារ | ៩៦វង់ | ពេញរដូវនេសាទ |
| សន្ទូច | ផ្លែ | ៣២ | ២០០ផ្លែ/គ្រួសារ | ៦.៤០០ផ្លែ | ខែសីហា ដល់ ខែមករា |
| អួនអូសដៃ | វង់ | ៨ | ៣០ម/១វង់/គ្រួសារ | ៣៤០ម/៨វង់ | ខែមករា ដល់ ខែមេសា |
| លាន់ | គ្រឿង | ៦ | ៥០គ្រឿង/គ្រួសារ | ៣០០គ្រឿង | ខែកញ្ញា ដល់ ខែធ្នូ |
| លបត្រីឆ្លាំង(បួម) | គ្រឿង | ៥ | ៣គ្រឿង/គ្រួសារ | ១៥គ្រឿង | ខែកក្កដា ដល់ ខែសីហា |
| លបក្ដាម | គ្រឿង | ១២ | ១០០-៤០០គ្រឿង/គ្រួសារ | ៣.០០០គ្រឿង | ខែសីហា ដល់ ខែកញ្ញា |
| លបត្រីខ្ទីង | គ្រឿង | ៥ | ១២គ្រឿង/គ្រួសារ | ៦០គ្រឿង | ខែសីហា ដល់ ខែកញ្ញា |
| លបបង្កង | គ្រឿង | ៨ | ៥០-១០០គ្រឿង/គ្រួសារ | ៦០០គ្រឿង | ខែសីហា ដល់ ខែតុលា |
| កន្ទ្រុំ | ដុំ | ៣៦ | ៦ដុំ/គ្រួសារ | ២១៦ដុំ | ខែកញ្ញា ដល់ ខែវិច្ឆិកា |
| កង្វាត្រីឆ្លូញ | គ្រឿង | ១៩ | ១គ្រឿង/គ្រួសារ | ១៩គ្រឿង | ខែមករា ដល់ ខែឧសភា |
| ថ្នង | គ្រឿង | ៦ | ១គ្រឿង/គ្រួសារ | ៦គ្រឿង | ខែកញ្ញា ដល់ ខែវិច្ឆិកា |
| ទ្រូ | គ្រឿង | ១៥ | ៤គ្រឿង/គ្រួសារ | ៦០គ្រឿង | ខែមករា ដល់ ខែឧសភា |
| ឡើ | គ្រឿង | ៨ | ៦គ្រឿង/គ្រួសារ | ៤៨គ្រឿង | ខែសីហា ដល់ ខែតុលា |
| ឈ្នាងត្រាំ | គ្រឿង | ៣ | ១គ្រឿង/គ្រួសារ | ៣គ្រឿង | ខែមករា ដល់ ខែកុម្ភៈ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ១៨គ្រឿង | ៥០០ - ១.០០០គីឡូក្រាម | ៦ - ៨ សេះ |
| ទូកអុំ និងចែវ | ៧គ្រឿង | ២០០ - ៥០០គីឡូក្រាម | |

ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន គ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ១៨៣ | ២០០ម-៥០០ម/គ្រួសារ | ៦៤.០៥០ម៉ែត្រ | ពេញរដូវនេសាទ |
| លបក្ដាម | គ្រឿង | ១៥ | ១០០-២០០គ្រឿង/គ្រួសារ | ២.២៥០គ្រឿង | ខែសីហា ដល់ ខែកញ្ញា |
| សន្ទូច | ផ្លែ | ៥ | ២០០ផ្លែ/គ្រួសារ | ១.០០០ផ្លែ | ខែសីហា ដល់ ខែមករា |
| សំណាញ់ | វង់ | ៤៣ | ១វង់/គ្រួសារ | ៤៣វង់ | ពេញរដូវនេសាទ |
| លាន់ | គ្រឿង | ៤ | ១០០គ្រឿង/គ្រួសារ | ៤០០គ្រឿង | ខែកញ្ញា ដល់ ខែធ្នូ |
| លបត្រីខ្ទីង | គ្រឿង | ៣ | ៤-៣០គ្រឿង/គ្រួសារ | ៨៥គ្រឿង | ខែសីហា ដល់ ខែកញ្ញា |
| លបបង្កង | គ្រឿង | ៥ | ៥០-១០០គ្រឿង/គ្រួសារ | ៣៧៥គ្រឿង | ខែសីហា ដល់ ខែតុលា |
| កន្ទ្រុំ | ដុំ | ១៥ | ៦-៣០ដុំ/គ្រួសារ | ២៧០ដុំ | ខែកញ្ញា ដល់ ខែវិច្ឆិកា |
| កង្វាត្រីឆ្លូញ | គ្រឿង | ២៧ | ១គ្រឿង/គ្រួសារ | ២៧គ្រឿង | ខែមករា ដល់ ខែឧសភា |
| ថ្នង | គ្រឿង | ១២ | ១គ្រឿង/គ្រួសារ | ១២គ្រឿង | ខែកញ្ញា ដល់ ខែវិច្ឆិកា |
| ទ្រូ | គ្រឿង | ១២ | ៤គ្រឿង/គ្រួសារ | ៤៨គ្រឿង | ខែមករា ដល់ ខែឧសភា |
| ឡើ | គ្រឿង | ៥ | ៦គ្រឿង/គ្រួសារ | ៣០គ្រឿង | ខែសីហា ដល់ ខែតុលា |
| ឈ្នាងត្រាំ | គ្រឿង | ២ | ១គ្រឿង/គ្រួសារ | ២គ្រឿង | ខែមករា ដល់ ខែកុម្ភៈ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៣៥គ្រឿង | ៥០០ - ១.០០០គីឡូក្រាម | ៦ - ៨ សេះ |
| ទូកអ៊ុំ និងចែវ | ១៨គ្រឿង | ២០០ - ៥០០គីឡូក្រាម | |

- ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ៤៥ | ៥០០-៨០០ម/គ្រួសារ | ២៩.២៥០ម៉ែត្រ | ពេញរដូវនេសាទ |
| លបក្តាម | គ្រឿង | ១៧ | ១០០-២០០គ្រឿង/គ្រួសារ | ២.៥៥០គ្រឿង | ខែសីហា ដល់ ខែកញ្ញា |
| លាន់ | គ្រឿង | ២ | ២០០គ្រឿង/គ្រួសារ | ៤០០គ្រឿង | ខែកញ្ញា ដល់ ខែធ្នូ |
| លបត្រីខ្ទឹង | គ្រឿង | ៨ | ២០-៣០គ្រឿង/គ្រួសារ | ២០០គ្រឿង | ខែសីហា ដល់ ខែកញ្ញា |
| លបបង្កង | គ្រឿង | ៥ | ៥០-១០០គ្រឿង/គ្រួសារ | ៣៧៥គ្រឿង | ខែសីហា ដល់ ខែតុលា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ១៨គ្រឿង | ៥០០ - ១.០០០គីឡូក្រាម | ៦ - ៨ សេះ |

គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គ្រួសារអ្នកនេសាទ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីចម្រុះ | ៧៩៨ គីឡូក្រាម | ៥៤៥ គីឡូក្រាម | ១.៣៤៣ គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

ក. ទស្សនៈវិស័យ ៖

សហគមន៍នេសាទព្រែកក្របៅ មានទស្សនៈវិស័យចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

ខ. គោលបំណង ៖

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុបពីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទកន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវតំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍រយៈពេល៣ឆ្នាំ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន (ក្នុងពេលតែមួយ) | |
| បឹង ព្រែក ប្រឡាយ និងក្នុងកន្លែងនេសាទសហគមន៍ព្រែកក្រចៅ | កក្កដា ដល់ វិច្ឆិកា | មងរាយ | ១០០ម៉ែត្រ | ៥០គ្រួសារ | -សមាជិកសហគមន៍ និងអ្នកមិនសមាជិកសហគមន៍ -ឧបករណ៍នេសាទធ្វើពីសាច់មងឬសាច់អួន ក្រឡាធំជាង ១,៥ សង្ទីម៉ែត្រ និងតូចជាង១៥សង្ទីម៉ែត្រ |
| | ធ្នូ ដល់ មិថុនា | | ៣០០ម៉ែត្រ | ៥០គ្រួសារ | |
| | សីហា ដល់ វិច្ឆិកា | លបឫស្សី | ៤គ្រឿង | ១៣គ្រួសារ | |
| | ពេញរដូវនេសាទ | សំណាញ់ | មិនកំណត់ | មិនកំណត់ | |
| | សីហា ដល់ មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ៣៥គ្រួសារ | |
| | ពេញរដូវនេសាទ | សន្ទូចបង្កៃ | ៣០ផ្លែ/គ្រួសារ | ៣៥គ្រួសារ | |
| | ពេញរដូវនេសាទ | សន្ទូចបបក់ | មិនកំណត់ | មិនកំណត់ | |
| | ពេញរដូវនេសាទ | សន្ទូចស្ទួច | មិនកំណត់ | មិនកំណត់ | |
| | មករា ដល់ មេសា | អួនអូសដៃ | ៣០ម/គ្រួសារ | ៦គ្រួសារ | |
| | កញ្ញា ដល់ ធ្នូ | លាន់ | ៣០គ្រឿង/គ្រួសារ | ២៥គ្រួសារ | |
| | កញ្ញា ដល់ សីហា | លបត្រីឆ្លាំង(បួម) | ៤គ្រឿង/គ្រួសារ | ៨គ្រួសារ | |
| | សីហា ដល់ កញ្ញា | លបក្ដាម | ៥០គ្រឿង/គ្រួសារ | ១៥គ្រួសារ | |
| | សីហា ដល់ កញ្ញា | លបត្រីខ្ជឹង | ១០គ្រឿង/គ្រួសារ | ១៥គ្រួសារ | |
| | សីហា ដល់ តុលា | លបបង្កង | ៥០គ្រឿង/គ្រួសារ | ១៥គ្រួសារ | |
| | កញ្ញា ដល់ វិច្ឆិកា | កន្ស៊ំ | ១៥ដុំ/គ្រួសារ | ៣០គ្រួសារ | |
| | កញ្ញា ដល់ វិច្ឆិកា | ថ្នង | មិនកំណត់ | មិនកំណត់ | |
| | មករា ដល់ឧសភា | កង្វាត្រីឆ្តោញ | មិនកំណត់ | មិនកំណត់ | |
| | មករា ដល់ ឧសភា | ទ្រូ | ៤គ្រឿង/គ្រួសារ | មិនកំណត់ | |
| | ឧសភាដល់សីហា | ប៉ោង | ២គ្រឿង/គ្រួសារ | មិនកំណត់ | |
| | សីហា ដល់ តុលា | ឡើ | ១០គ្រឿង/គ្រួសារ | មិនកំណត់ | |
| ទំនាបលិចទឹកក្នុងកន្លែងនេសាទសហគមន៍ព្រែកក្រចៅ ទំហំ១.០៦៩ ហិកតា | កក្កដា ដល់ វិច្ឆិកា | មងរាយ | ១០០ម៉ែត្រ | ៥០គ្រួសារ | -សមាជិកសហគមន៍ និងអ្នកមិនសមាជិកសហគមន៍ -ឧបករណ៍នេសាទធ្វើពីសាច់មងឬសាច់អួន ក្រឡាធំជាង ១,៥ សង្ទីម៉ែត្រ និងតូចជាង១៥សង្ទីម៉ែត្រ |
| | ធ្នូ ដល់ មិថុនា | | ៣០០ម៉ែត្រ | ៧០គ្រួសារ | |
| | សីហា ដល់ វិច្ឆិកា | លបឫស្សី | ៤គ្រឿង | ១៣គ្រួសារ | |
| | ពេញរដូវនេសាទ | សំណាញ់ | មិនកំណត់ | មិនកំណត់ | |
| | សីហា ដល់ មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ៣៥គ្រួសារ | |
| | ពេញរដូវនេសាទ | សន្ទូចបង្កៃ | ៣០ផ្លែ/គ្រួសារ | ៣៥គ្រួសារ | |
| | ពេញរដូវនេសាទ | សន្ទូចបបក់ | មិនកំណត់ | មិនកំណត់ | |
| | ពេញរដូវនេសាទ | សន្ទូចស្ទួច | មិនកំណត់ | មិនកំណត់ | |
| | កញ្ញា ដល់ ធ្នូ | លាន់ | ៣០គ្រឿង/គ្រួសារ | ២៥គ្រួសារ | |

| | | | | | |
|---|---|---|---|---|---|
| | កញ្ញា ដល់ សីហា | លបត្រីឆ្លាំង(ប្រូម) | ៨គ្រឿង/គ្រួសារ | ៨គ្រួសារ | |
| | សីហា ដល់ កញ្ញា | លបក្តាម | ៥០គ្រឿង/គ្រួសារ | ១៥គ្រួសារ | |
| | សីហា ដល់ កញ្ញា | លបត្រីខ្វឹង | ១០គ្រឿង/គ្រួសារ | ១៥គ្រួសារ | |
| | សីហា ដល់ តុលា | លបបង្កង | ៥០គ្រឿង/គ្រួសារ | ១៥គ្រួសារ | |
| | កញ្ញា ដល់ វិច្ឆិកា | កន្ទុំ | ១៥ដុំ/គ្រួសារ | ៣០គ្រួសារ | |
| | កញ្ញា ដល់ វិច្ឆិកា | ថ្នង | មិនកំណត់ | មិនកំណត់ | |
| | មករា ដល់ឧសភា | កង្វាត្រីឆ្លូញ | មិនកំណត់ | មិនកំណត់ | |
| | មករា ដល់ ឧសភា | ទ្រូ | ៤គ្រឿង/គ្រួសារ | មិនកំណត់ | |
| | ឧសភាដល់សីហា | ប៉ោង | ៤គ្រឿង/គ្រួសារ | មិនកំណត់ | |
| | សីហា ដល់ តុលា | ឡើ | ១០គ្រឿង/គ្រួសារ | មិនកំណត់ | |

## គ.២ ផែនការកែលម្អកន្លែងនេសាទសហគមន៍

ផែនការកែលម្អដែននេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ដែននេសាទ | ទំហំ (ហត) | ទំហំដែលត្រូវកែលម្អ (ហត) | សកម្មភាព | ប៉ាន់ប្រមាណថវិកា(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍ | ១.០៦៩ | ១.០៦៩ | ប្រជុំផ្សព្វផ្សាយ | ៣០០ | ៧/២០១៩ | ២០២០ |
| | | | កំណត់ទីតាំងតាមនិយាមកា | ២៥០ | | |
| | | | បោះបង្គោលព្រំ៩បង្គោល | ១.៨០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៣៣០ | | |
| ព្រែកអាហ្វូរ | ៦០ម x ១.៨០០ម | ជ.៤ម-ទ.១០ម x ប.១.០០០ម = ៤០.០០០ម៣ | កំណត់ទីតាំងដាក់ស្តែង | ១០០ | ២០២០ | ២០២១ |
| | | | ប្រជុំផ្សព្វផ្សាយជាមួយអ្នកពាក់ព័ន្ធ | ៣០០ | | |
| | | | គ្រឿងចក្រស្តារឡើងវិញ ចំនួន១៦០ម៉ោង | ៩.៩២០ ៦២/១ម៉ោង | | |
| | | | ឡានដឹកអាចម៍ដីរៀបចំនៅមាត់ព្រែក | ៨.០០០ | | |
| ដៃព្រែកអាហ្វូរ | ១០មx ៨០០ម | ជ.៤ម-ទ.៥ម x ប.៨០០ម = ១៦.០០០ម៣ | កំណត់ទីតាំងដាក់ស្តែង | ១០០ | ២០២០ | ២០២១ |
| | | | ប្រជុំផ្សព្វផ្សាយជាមួយអ្នកពាក់ព័ន្ធ | ៣០០ | | |
| | | | គ្រឿងចក្រស្តារឡើងវិញ ចំនួន៦៤ម៉ោង | ៣.៩៦៨ ៦២/១ម៉ោង | | |
| | | | ឡានដឹកអាចម៍ដីរៀបចំដាក់តាមមាត់ដៃព្រែក | ៣.២០០ | | |
| ព្រែកអាមួយ | ៤០មx ១.៧០០ម | ជ.៤ម-ទ.៥ម x ប.១.០០០ម = ២០.០០០ម៣ | កំណត់ទីតាំងដាក់ស្តែង | ១០០ | ២០២១ | ៦/២០២២ |
| | | | ប្រជុំផ្សព្វផ្សាយជាមួយអ្នកពាក់ព័ន្ធ | ៣០០ | | |
| | | | គ្រឿងចក្រស្តារឡើងវិញ ចំនួន៨០ម៉ោង | ៤.៩៦០ ៦២/១ម៉ោង | | |
| | | | ឡានដឹកអាចម៍ដីរៀបចំដាក់តាមមាត់ព្រែក | ៤.០០០ | | |

| | | | | | | |
|---|---|---|---|---|---|---|
| ព្រែកគូយ៉ាវ | ២០មx ១.៧០០ម | ជ.៤ម-ទ.៥ម x ប.១.០០០ម = ២០.០០០ម$^{៣}$ | កំណត់ទីតាំងជាក់ស្តែង | ១០០ | ២០២១ | ៦/២០២២ |
| | | | ប្រជុំផ្សព្វផ្សាយជាមួយអ្នកពាក់ព័ន្ធ | ៣០០ | | |
| | | | គ្រឿងចក្រស្តារឡើងវិញ ចំនួន៨០ម៉ោង | ៤.៩៦០ ៦២/១ម៉ោង | | |
| | | | ឡានដឹកអាចម៍ដីរៀបចំនៅមាត់ព្រែក | ៤.០០០ | | |

**គ.៣ ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស**

ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះដែននេសាទ | ទំហំត្រូវអភិរក្ស (ហិកតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណថវិកា (ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| -បឹងដងរ៉ែក ១៣,២ហិកតា -បឹងបាក់បែង ១០ហិកតា | ផ្ទៃបឹងទាំង២ | ត្រីមេពូជ ព្រៃលិចទឹក | ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងការហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ (បីលើក) | ៦០០ | ៧/២០១៩ | ២០២១ |
| | | | កំណត់ទីតាំង និងនិយាមកា | ៤០០ | ៧/២០១៩ | ២០២១ |
| | | | បោះបង្គោលព្រំធ្វើពីបេតុងតំបន់អភិរក្សចំនួន៤បង្គោល | ៧.២០០ | ៧/២០១៩ | ២០២១ |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៣៣០ | ៧/២០១៩ | ២០២១ |
| | | | សង់ប៉មយាមការពារកន្លែងអភិរក្សធ្វើពីបេតុងគ្រឿងដែកប្រក់ស្បូវ (៣មx៤មx៨ម) | ៥.០០០ | ៧/២០១៩ | ២០២១ |
| | | | លែងត្រីពូជធម្មជាតិ ៤០០គីឡូ | ២.៦០០ | ២០២០ | ២០២១ |
| | | | យាមល្បាតការពារកន្លែងអភិរក្ស | | ៧/២០១៩ | ៦/២០២២ |

**គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក**

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំឡើងវិញ ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទព្រៃឈើការពារ | សកម្ម ភាព | | ប៉ាន់ប្រមាណថវិកា (ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|---|
| -បឹងដងរ៉ែក -បឹងបាក់បែង | កន្លែងមានព្រៃលិចទឹកក្នុងតំបន់បឹងទាំង២ | ព្រៃលិចទឹក | ផ្សព្វផ្សាយពីកន្លែងព្រៃលិចទឹកឱ្យបានទូលំទូលាយ | បិទឯកសារ | ៤០០ | ២០២០ | ២០២១ |
| | | | | ប្រជុំ | ៨០០ | | |
| | | | ចុះពិនិត្យ និងកំណត់ទីតាំងជាក់ស្តែង | | ៣០០ | ២០២០ | ២០២១ |
| | | | បោះបង្គោលព្រំព្រៃលិចទឹកចំនួន ៤០ បង្គោល | | ២.៦០០ | ២០២០ | ២០២១ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | (០,២ម×៣ម/ជើងតាង/ប្រើដែក១២លីនិង៦លី) និងសរសេរស្លាកសញ្ញា | | | |
| | | | ថែរក្សា ការពារ | | ៧/២០១៩ | ៦/២០២២ |

គ៥-ផែនការទប់ស្កាត់បទល្មើសជលផល

ផែនការចុះទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំឡើងមានដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណថវិកា (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយ ៖<br>-ផ្សព្វផ្សាយតាមមេក្រូ ៣ថ្ងៃ/ឆ្នាំ<br>-ផ្សព្វផ្សាយបិទឯកសារ១ដង/ឆ្នាំ<br>-ប្រជុំផ្សព្វផ្សាយ១ដង/ឆ្នាំ មិថុនា/រៀងរាល់ឆ្នាំ | -មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទ សារៈសំខាន់នៃធនធានជលផល និងការគ្រប់គ្រងសហគមន៍នេសាទ<br>-ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ | ១.៥៦០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | ៧/២០១៩ | ២០២១ |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការល្បាតប្រចាំត្រីមាស និងឆមាស (មករា និងមិថុនា) | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ<br>-មានផែនការសមស្របជាក់លាក់ ដើម្បីចុះអនុវត្តន៍ការងារ | ៤២០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ | ៧/២០១៩ | ៦/២០២២ |
| សហការជាមួយអាជ្ញាធរមូលដ្ឋានជលផល និងប៉ូលិសប៉ុស្តិ៍ ដើម្បីអញ្ជើញអ្នកនេសាទខុសច្បាប់ធ្វើកិច្ចសន្យាឈប់ប្រព្រឹត្តបទល្មើសនិងផ្តល់ឧបករណ៍ខុសច្បាប់ | -កាត់បន្ថយការនេសាទខុសច្បាប់<br>-បញ្ឈប់អ្នកនេសាទខុសច្បាប់<br>-ធនធានជលផលកើនឡើង | ៦០០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ប៉ូលិសប៉ុស្តិ៍ | ៧/២០១៩ | ៦/២០២២ |
| អនុវត្តន៍ផែនការ៖ (រៀបចំកំលាំងចុះបង្ក្រាបដល់ទីកន្លែងដោយទំនាក់ទំនង និងសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូ) (៤ដង/ខែ = ១៤៤/ដង) | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកស.នធូរធារ | ៩.៣៦០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ | ៧/២០១៩ | ៦/២០២២ |
| មធ្យោបាយនិងសម្ភារៈ<br>-សាំង និងប្រេងបាត<br>-អាវភ្លៀង អាវពោង ពិល មួក<br>-កាតទូរស័ព្ទ អាយកូមទាក់ទង<br>-ម៉ាស៊ីនថត កែវយឹត | មានលទ្ធភាពចុះល្បាតដោយមានប្រសិទ្ធិភាពខ្ពស់ | ៣.៣៤៦ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ | ៧/២០១៩ | ៦/២០២២ |
| ទិញទូកម៉ាស៊ីនថ្មីចំនួន១គ្រឿង | មានមធ្យោបាយចុះល្បាត | ១.៥០០ | | ២០២១ | ៦/២០២២ |

គ៦-ផែនការប្រជុំប្រចាំខែ និងទិញសម្ភារអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ

ផែនការប្រជុំប្រចាំខែ និងទិញសម្ភារអនុវត្តន៍ការងារ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណថវិកា (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំគណៈកម្មការសហគមន៍នេសាទនៅសប្តាហ៍ទី៣ នៃខែរៀងរាល់ខែ | -របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-មានផែនការអនុវត្តន៍បន្ត | ៣៦០ | -គណៈកម្មការ<br>-ក្រុមល្បាត | ៧/២០១៩ | ៦/២០២២ |
| ប្រជុំជាមួយអាជ្ញាធរឃុំ ឬស្ថាប័នពាក់ព័ន្ធ (១០-៣០/រៀងរាល់ខែ) | -ទទួលព័ត៌មាន និងផ្តល់របាយការណ៍លទ្ធផលសម្រេចបាន<br>-លើកបញ្ហាដាក់ចូលរបៀបវារៈនៃកិច្ចប្រជុំ ដើម្បីដោះស្រាយ<br>-បញ្ចូលផែនការទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ និងផែនការស្ថាប័នពាក់ព័ន្ធ | ៥៤០ | -អាជ្ញាធរឃុំ<br>-គណៈកម្មការ<br>-ស្ថាប័នពាក់ព័ន្ធ | ៧/២០១៩ | ៦/២០២២ |
| សម្ភារការិយាល័យ៖<br>-ទិញក្រដាស់ ប៊ិច កំព្យូទ័រ<br>-ព្រីនឯកសារ<br>-ការទំនាក់ទំនង | មានសម្ភារការិយាល័យសម្រាប់ប្រើប្រាស់ | ៨៩០ | គណៈកម្មការ | ៧/២០១៩ | ៦/២០២២ |

គ៧-ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាលត្រូវបានរៀបចំឡើង ដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទមានដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណថវិកា (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការផ្សព្វផ្សាយ | | | | | |
| ប្រជុំផ្សព្វផ្សាយអំពីច្បាប់<br>-ផលផល ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងស.ន<br>-លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍<br>-ការប្រើប្រាស់និងការទុកដាក់ថ្នាំកសិកម្ម<br>-អំពើហិង្សាក្នុងគ្រួសារ និង<br>-បទពិសោធន៍ដែលទទួលបាន | -សមាជិកសហគមន៍នេសាទ និងអ្នកខាងក្រៅមានការយល់ដឹងនិងអនុវត្តន៍តាម<br>-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តន៍តាមផែនការនិងវិធានច្បាប់នានាដែលបានផ្សព្វផ្សាយ<br>-ផលត្រីនៅក្នុងសហកមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើននាំឱ្យជីវភាពធូរធារនិងគ្មានអំពើហឹង្សាក្នុងគ្រួសារ | ២.៥៨០ | សហគមន៍នេសាទ និងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋាន ជំនាញផលផល អង្គការដៃគូ | ឧសភា-មិថុនា (រៀងរាល់ឆ្នាំ) | |
| បិទផ្សាយឯកសារ ១ដង/ឆ្នាំ | | ១៦០ | | ២០២០ | ២០២២ |

| | | | | | |
|---|---|---|---|---|---|
| -ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ<br>-ចែកចាយឯកសារនានា | | ៤៥០ | | ២០២០ | ២០២២ |
| ផ្សព្វផ្សាយជ្រើសរើសក្រុមយុវជននិងប្រជាពលរដ្ឋចូលជាសមាជិកសហគមន៍នេសាទព្រៃកក្រៅ | មានយុវជននិងប្រជាពលរដ្ឋចូលរួមក្នុងការងារគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ | ១.២០០ | សហគមន៍នេសាទ | ២០២០ | ២០២១ |
| ផែនការបណ្តុះបណ្តាល | | | | | |
| វគ្គបណ្តុះបណ្តាលពី ៖<br>-របៀបរៀបចំលិខិតរដ្ឋបាល<br>-របាយការណ៍<br>-កំណត់ហេតុ<br>-គម្រោងស្នើសុំថវិកា<br>-គម្រោងថវិកានិងការគ្រប់គ្រងថវិកាស.ន | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តន៍បាន ក្នុងការងារជាក់ស្តែង | ១.៤០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | ៧/២០១៩ | ២០២០ |
| វគ្គបណ្តុះបណ្តាលពីកំព្យូទ័រ | គណៈសហគមន៍នេសាទ(២នាក់) | ៣២៥ | គណៈកម្មការស.ន | ២០២០ | ២០២១ |
| វគ្គបណ្តុះបណ្តាលពី ៖<br>-ការគ្រប់គ្រងនិងសារៈសំខាន់នៃធនធានធម្មជាតិ<br>-សិទ្ធិជាមូលដ្ឋានលើធនធានធម្មជាតិ | គណៈកម្មការសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តន៍បាន ក្នុងការងារជាក់ស្តែង | ៦៥០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន | ២០២០ | ២០២១ |
| វគ្គបណ្តុះបណ្តាលយេនឌ័រ និងការវិភាគយេនឌ័រ | | ៤០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន | ២០២០ | ២០២១ |
| វគ្គបណ្តុះបណ្តាលវិធីសាស្ត្រការប្រមូលព័ត៌មាន | គណៈកម្មការសហគមន៍នេសាទ បានយល់ដឹងនិងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ៤០០ | គណៈកម្មការស.ន | ២០២០ | ២០២១ |
| វគ្គបណ្តុះបណ្តាលពីការប្រែប្រួលអាកាសធាតុ | គណៈកម្មការសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តន៍បាន | ៥០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន | ២០២០ | ២០២១ |
| វគ្គបណ្តុះបណ្តាលការរៀបចំផែនការអាជីវកម្ម | | ៦០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន | ២០២១ | ៦/២០២២ |
| វគ្គបណ្តុះបណ្តាលពីការសម្របសម្រួលដោះស្រាយទំនាស់ | គណៈកម្មការ និងសមាជិកស.ន បានយល់ដឹង និងអាចអនុវត្តន៍ បានក្នុងការងារជាក់ស្តែង | ៤០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន | ២០២១ | ៦/២០២២ |

គ៨- ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ

ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណថវិកា (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការបណ្តុះបណ្តាល | | | | | |
| ចិញ្ចឹម (ត្រី កង្កែប អន្ទង់) | -មានចំណេះដឹង<br>-មានមុខរបរ<br>-បង្កើនប្រាក់ចំណូល | ១.៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០២០ | ៦/២០២២ |
| កែច្នៃផល និងផលិតផលផលផល | | ១.៥០០ | | ២០២០ | ៦/២០២២ |
| បច្ចេកទេសដាំបន្លែ | | ៩០០ | | ២០២០ | ៦/២០២២ |
| បច្ចេកទេសកសិកម្មចម្រុះ និងកសិកម្មបន្ត | | ៩០០ | | ២០២០ | ៦/២០២២ |
| ជំនាញវិជ្ជាជីវៈលើការផ្តល់សេវាទស្សនាកំសាន្ត | -ក្រុមចុងភៅ<br>-ក្រុមផ្ទះស្នាក់នៅ<br>-ក្រុមដឹកជញ្ជូន<br>-ក្រុមធ្វើរយានយន្ត<br>-ក្រុមផ្គត់ផ្គង់ផលិតផលកសិកម្ម<br>-ក្រុមរោងលម្ហែ (កញ្ចុះ) | ១.០០០ | គណៈកម្មការនិងសមាជិកស.ន | ២០២០ | ៦/២០២២ |
| ទស្សនៈកិច្ចសិក្សា | | ២.៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០២០ | ៦/២០២២ |
| ផែនការបង្កើតក្រុមមុខរបរ | | | | | |
| ក្រុមកែច្នៃផលិតផលផលផល ដោយផ្តោតលើក្រុមស្ត្រីនិងក្រុមងាយរងគ្រោះ | -គណៈកម្មការនិងសមាជិកសហគមន៍នេសាទបង្កើតឡើងជាក់ស្តែង<br>-មានផលិតផលផលផលផ្គត់ផ្គង់ដល់តំបន់ទស្សនាកំសាន្តនិងទីផ្សារ<br>-មានមុខរបរបង្កើនប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០២០ | ៦/២០២២ |
| ក្រុមដាំបន្លែ | -គណៈកម្មការនិងសមាជិកសហគមន៍នេសាទបង្កើតឡើងជាក់ស្តែង<br>-មានបន្លែផ្គត់ផ្គង់ដល់តំបន់ទស្សនាកំសាន្ត និងទីផ្សារ<br>-មានមុខរបរបង្កើនប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០២០ | ៦/២០២២ |
| ក្រុមកសិកម្មចម្រុះ និងកសិកម្មបន្ត | -មានក្រុមកសិកម្មចម្រុះ និងបន្ត<br>-មានដំណាំចម្រុះផ្គត់ផ្គង់ដល់កន្លែងកំសាន្តនិងទីផ្សារ<br>-មានមុខរបរនិងប្រាក់ចំណូល | ៨០០ | គណៈកម្មការនិងសមាជិស.ន | ២០២០ | ៦/២០២២ |

គ៩- ផែនការបង្កើតសហគមន៍នេសាទទេសចរណ៍ធម្មជាតិ

ផែនការបង្កើតសហគមន៍នេសាទទេសចរណ៍ធម្មជាតិព្រៃកក្រពៅ ត្រូវបានរៀបចំឡើងនៅចំណុចព្រៃកអាហួរ និងក្នុងកន្លែងនេសាទសហគមន៍ មានដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណថវិកា (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំផ្សព្វផ្សាយ<br>-លើកដំបូង<br>-ដំណើរការរួច | គណៈកម្មការនិងសមាជិកសហគមន៍នេសាទបានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ១.១០០ | សហគមន៍នេសាទ អាជ្ញាធរភូមិ ឃុំនិងស្រុក ជំនាញផលផល ប៉ូលីស និងអង្គការដៃគូ | ៧/២០១៩ | ២០២១ |
| ទស្សនៈកិច្ចសិក្សា | មានបទពិសោធន៍ស្តីពីការរៀបចំសហគមន៍នេសាទទេសចរណ៍ | ១.៥៣៥ | | ៧/២០១៩ | ២០២១ |
| រៀបចំទីតាំងទេសចរណ៍ធម្មជាតិ៖<br>- ស្លាកសញ្ញាទីតាំងចំនួន១<br>-សាងសង់រោងប្រជុំ<br>-សង់រោងលម្ហែចំនួន៥<br>-ទូកដឹកជញ្ជូនភ្ញៀវចំនួន៣<br>-ធុងសម្រាមចំនួន៨<br>-បង្គន់អនាម័យ(បុរស/ស្ត្រី)<br>-បណ្តាញអគ្គិសនី<br>-ផលិតសៀវភៅណែនាំ និងផ្សព្វផ្សាយ | ដំណើរការបង្កើតសហគមន៍នេសាទទេសចរណ៍ធម្មជាតិទទួលបានជោគជ័យ | ១២.៩០០ | | ៧/២០១៩ | ៦/២០២២ |
| បង្កើតក្រុម | -ក្រុមបដិសណ្ឋារកិច្ច<br>-ក្រុមសេវាម្ហូបអាហារ<br>-ក្រុមរោងសម្រាកលម្ហែ<br>-ក្រុមផ្ទះស្នាក់នៅ<br>-ក្រុមអាវពោងហែលទឹក<br>-ក្រុមដឹកជញ្ជូន<br>-ក្រុមផ្ញើរយានយន្ត<br>-ក្រុមផ្គត់ផ្គង់ផលិតផលកសិកម្ម<br>-ក្រុមលក់ផលិតផលកែច្នៃ<br>-ក្រុមកសិកម្មបង្ហាញ | ១.២០០ | សហគមន៍នេសាទ អាជ្ញាធរភូមិ ឃុំនិងស្រុក ជំនាញផលផលនិងអង្គការដៃគូ | ៧/២០១៩ | ៦/២០២២ |
| ប្រជុំរៀបចំគោលការណ៍ផ្ទៃ ក្នុងរបស់ក្រុមមុខរបរ | មានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងនៃក្រុមនីមួយៗក្នុងការអនុវត្ត | ៨០០ | គណៈកម្មការ និង សមាជិកស.ន | ៧/២០១៩ | ៦/២០២២ |
| សន្តិសុខ សណ្តាប់ធ្នាប់និង អនាម័យ | ធានាសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យក្នុងតំបន់ទស្សនាកំសាន្ត | ១.២០០ | គណៈកម្មការនិង សមាជិកស.ន | ៧/២០១៩ | ៦/២០២២ |

គ១០- ផែនការបង្កើតក្រុមឥណទាន(សន្សំប្រាក់) ដើម្បីបង្កើនមុខរបរ

ផែនការបង្កើតក្រុមឥណទាន(សន្សំប្រាក់) ដើម្បីបង្កើនមុខរបរ ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណថវិកា (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយ ជ្រើសរើសសមាជិកក្រុមសន្សំប្រាក់ | ក្រុមសន្សំប្រាក់ឥណទានសហគមន៍នេសាទព្រែកក្របៅត្រូវបានបង្កើតឡើងដោយគណៈកម្មការ និងសមាជិកស.ន | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ៧/២០១៩ | ៦/២០២២ |
| ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងក្រុមសន្សំប្រាក់ | -មានលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមសន្សំប្រាក់<br>-មានដំណើរការល្អ (ខ្ចី សង) | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ៧/២០១៩ | ៦/២០២២ |
| ផ្ដល់ទុនឥណទាន និងប្រមូលប្រាក់សន្សំ | មានទុនសម្រាប់កម្ចីនិងការចាប់ផ្ដើមមុខរបរ | ២.៥០០ | គណៈកម្មការនិងសមាជិកស.ន | ៧/២០១៩ | ៦/២០២២ |
| ប្រជុំប្រចាំខែ | -របាយការណ៍សាច់ប្រាក់<br>-ការរីកចម្រើននូវមុខរបរ | ២៧០ | ក្រុមសន្សំប្រាក់ | ៧/២០១៩ | ៦/២០២២ |

គ១១-ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ

ផែនការសម្រាប់អភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទចិញ្ចឹម | បរិមាណពូជ (កូន) | ប៉ាន់ស្មានថវិកា(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមកង្កែប អន្ទង់តាមអាង/ធុង (៨គ្រួសារ) | ៤អ/ធx៣មx៣មx១ម (៤០ក្បាល/ម៉ែត្រការ៉េ) | អន្ទង់ | ១.៤៤០/១ឆ្នាំ | ៨០០ | ២០២០ | ៦/២០២២ |
| | ៨ធង់x៥មx៣មx១,២ម (៨០ក្បាល/ម៉ែត្រការ៉េ) | កង្កែប | ៤.៨០០/១ឆ្នាំ | ១.៨០០ (៥០០៛/ក) | ២០២០ | ៦/២០២២ |

គ១២- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ

ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទព្រែកក្របៅ នៅចំណុចព្រែកទប់ ក្រោយមណ្ឌលសុខភាព ភូមិព្រែកក្រៅ ឃុំព្រែកក្របៅ ស្រុកពាមជរ ទំហំ២០ម x ៥០ម ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណថវិកា (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| សាងសង់ស្នាក់ការសហគន៍នេសាទ ទំហំ៦មx៨ម ធ្វើពីបេតុង ប្រក់ក្បឿង និងមានបង្គន់អនាម័យ | -សហគមន៍នេសាទមានការិយាល័យសម្រាប់ធ្វើការ<br>-មានលទ្ធភាពពេញលេញក្នុងការគ្រប់គ្រងសហគមន៍នេសាទ | ៨.៥០០ | គណៈកម្មការ សមាជិកស.ន ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០២០ | ២០២១ |

| | | | | | |
|---|---|---|---|---|---|
| បណ្តាញអគ្គីសនី | មានថាមពលអគ្គីសនីសម្រាប់សហគមន៍នេសាទធ្វើការងារ | ២៥០ | | ២០២០ | ២០២១ |
| សម្ភារសហគមន៍នេសាទ ៖ (តុ ទូ ក្តារខៀន កៅអី កំព្យូទ័រ ព្រីនធើ) | មានសម្ភារៈសម្រាប់ស.នធ្វើការ | ១.៥០០ | | ២០២០ | ២០២១ |

**គ១៣-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍**

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទ ប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ចំណូល ដុល្លា | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានសមាជិកភាពសហគមន៍នេសាទ | -ផ្សព្វផ្សាយការចូលជាសមាជិក និងបង់ប្រាក់សមាជិកភាព<br>-ប្រមូលភាគទាន២០០រៀល/ម្នាក់។ | ៧/២០១៩ | ៦/២០២២ | ៣២,៨៥ | ប៉ាន់ប្រមាណចំនួន ៩០% បានបង់នៃចំនួន៧៣០នាក់ |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយដល់សមាជិកបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំពីសមាជិក។ សហគមន៍នេសាទ២.០០០រៀល/ម្នាក់ | ៧/២០១៩ | ៦/២០២២ | ៦៥៧ | ប៉ាន់ប្រមាណចំនួន ៦០% បានបង់នៃចំនួន៧៣០នាក់ |
| កម្រៃអ្នកនេសាទមិនមែនជាសមាជិក និងអ្នកមកពីក្រៅ | ប្រមូលប្រាក់កម្រៃពីអ្នកនេសាទមិនមែនជាសមាជិកចំនួន១២០នាក់ ចំនួន ១០.០០០រៀល/គ្រួសារ/រដូវនេសាទ និងអ្នកមកពីខាងក្រៅចំនួន៨៥នាក់ ត្រូវបង់ចំនួន ១០០.០០០រៀល/គ្រួសារ/រដូវនេសាទ ។ | ៧/២០១៩ | ៦/២០២២ | ៤.២៧៥ | ប៉ាន់ប្រមាណ អ្នកនេសាទមិនមែនជាសមាជិកចំនួន៥០% និងអ្នកមកពីខាងក្រៅ ៦០% បានបង់ប្រាក់កម្រៃ |
| សរសេរគម្រោងស្នើសុំថវិកាពី ៖<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូពាក់ព័ន្ធ<br>-សប្បុរសជន | ទំនាក់ទំនងជាមួយ ៖<br>-មន្ទីរពាក់ព័ន្ធជុំវិញខេត្ត<br>-អង្គការដៃគូពាក់ព័ន្ធ<br>-សប្បុរសជន<br>-សរសេរគម្រោងស្នើសុំ<br>-តាមដាន និងវាយតម្លៃ | ៧/២០១៩ | ៦/២០២២ | ១៣៦.១៤៩ | សរសេរគម្រោងស្នើសុំថវិកាចំណាយ ៥០០ដុល្លា |
| សរុប | | | | ១៤១.១១៤ | |

ឃ. ផែនការយុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តន៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការរួមមាន សមាជិកនិងគណៈកម្មការសហគមន៍នេសាទចាស់ទុំ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗ ជាពិសេសបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទង និងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែង អភិរក្សព្រៃលិចទឹក កន្លែង អភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្របច្ចេកទេសនិងថវិការសម្រាប់ដំណើរការអនុវត្តន៍ផែនការ
- រៀបចំផែនការអនុវត្តន៍តាមដំណាក់កាលនីមួយៗ ដោយជាក់លាក់និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលនិងស្ថាប័នពាក់ព័ន្ធដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- ធ្វើសមាហរណកម្មបញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ
- រៀបចំធ្វើស្នាក់ការសហគមន៍នេសាទចំនួនមួយខ្នងនិងទិញទូកម៉ាស៊ីនចំនួន១គ្រឿងសម្រាប់គ្រប់គ្រង និងថែរក្សា ការពារកន្លែងនេសាទសហគមន៍។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ព្រែកក្របៅ រយៈពេល ៣ ឆ្នាំ (ខែកក្កដា ឆ្នាំ២០១៩ ដល់ មិថុនា ឆ្នាំ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ធ្វើនេសាទ | -ប្រើប្រាស់ឧបករណ៍សមស្រប<br>-មាននិរន្តរភាពធនធានមច្ឆជាតិ<br>-បង្កើនប្រាក់ចំណូល | | សមាជិកនិង<br>គណៈកម្មការ | ៧/២០១៩ | ៦/២០២២ | |
| គ២.ផែនការកែលម្អកន្លែងនេសាទសហគមន៍ | -ប្រជុំផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ<br>-កំណត់ទីតាំងជាក់ស្ដែងតាមនិយាមកា<br>-បោះបង្គោលព្រំនិងសរសេរស្លាកសញ្ញា | -ស្គាល់ព្រំប្រទល់ច្បាស់លាស់<br>-ត្រីមានទីជម្រក<br>-ព្រៃលិចទឹកបានគង់វង្ស<br>-ត្រីកើន<br>-មានទឹកប្រើប្រាស់ | ២.៦៨០ | - ស.ន.ព.ក.ប<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ៧/២០១៩ | ៦/២០២២ | |
| | -កំណត់ទីតាំងជាក់ស្ដែង<br>-ប្រជុំផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ<br>-គ្រៀងចក្រស្ដារឡើងវិញ<br>-ឡានដឹកអាចម៍ដីរៀបចំដាក់មាត់ព្រែក | | ៨៤.៦០៨ | | ២០២០<br>២០២០ | ២០២១<br>៦/២០២២ | |
| គ៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | -ផ្សព្វផ្សាយ និងហាមឃាត់ឱ្យបានទូលំទូលាយ<br>-កំណត់ទីតាំង និងនិយាមកា<br>-បោះបង្គោលព្រំ និងដាក់ស្លាកសញ្ញា<br>-សាងសង់ប៉មយាម<br>-យាមល្បាតការពារកន្លែងអភិរក្ស | -មានទីជម្រកនិងមានត្រីមេពូជ<br>-ត្រីកើនឡើងវិញ<br>-ព្រៃលិចទឹកកើនឡើងវិញ<br>-ធនធានផលផលបានគង់វង្ស | ១៦.១៣០ | - ស.ន.ព.ក.ប<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ៧/២០១៩ | ៦/២០២២ | |
| | លែងត្រីពូជធម្មជាតិ | | | | ២០២០ | ២០២១ | |
| គ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | -ផ្សព្វផ្សាយឱ្យបានទូលំទូលាយ<br>-កំណត់ទីតាំងជាក់ស្ដែង<br>-បោះបង្គោលព្រំព្រៃលិចទឹកនិងសរសេរស្លាកសញ្ញា | -ព្រៃលិចទឹកបានគង់វង្ស<br>-ជាជម្រកត្រី | ៤.១០០ | - ស.ន.ព.ក.ប<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០២០ | ២០២១ | |
| | ថែរក្សា ការពារ | | | | ៧/២០១៩ | ៦/២០២២ | |
| គ៥.ផែនការទប់ស្កាត់បទល្មើសផលផល | -ផ្សព្វផ្សាយមេក្រូ បិទ/ចែកឯកសារ ប្រជុំ<br>-ប្រជុំរៀបចំផែនការល្បាត<br>-ធ្វើកិច្ចសន្យាអ្នកនេសាទខុសច្បាប់<br>-អនុវត្តន៍ផែនការចុះបង្ក្រាបជាក់ស្ដែង | -បទល្មើសថយចុះ<br>-ធនធានព្រៃលិចទឹកនិងត្រីកើនឡើងវិញ<br>-ផលចាប់ត្រីបានច្រើន | ១៦.៧៨៦ | - ស.ន.ព.ក.ប<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ៧/២០១៩ | ៦/២០២២ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ទិញមធ្យោបាយនិងសម្ភារប្រើប្រាស់ | មានមធ្យោបាយ សម្ភារល្អាត | ៤.៦៤៦ | | ៧/២០១៩ | ៦/២០២២ | |
| គ៦.ផែនការប្រជុំប្រចាំខែ និងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ | -ប្រជុំគណៈកម្មការសហ គមន៍នេសាទ<br>-ប្រជុំជាមួយអាជ្ញាធរ/ស្ថាប័នពាក់ព័ន្ធ<br>-ទិញសម្ភារការិយាល័យ | -របាយការណ៍លទ្ធផល១៨ សម្រេចបានប្រចាំខែ<br>-មានសម្ភារការិយាល័យ សម្រាប់ប្រើប្រាស់ | ១.៧៩០ | - ស.ន.ព.ក.ប<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ៧/២០១៩ | ៦/២០២២ | |
| គ៧.ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល | ផ្សព្វផ្សាយ (ប្រជុំ បិទផ្សាយ ចែកឯកសារ)៖ ច្បាប់ជលផល ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងស.ន, លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង, ផែនការគ្រប់គ្រងស.ន, ការប្រើប្រាស់ថ្នាំកសិកម្ម អំពើហឹង្សាក្នុងគ្រួសារ និងបទពិសោធន៍ទទួលបាន | -គណៈកម្មការនិងសមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋមានចំណេះដឹងនិងបទពិសោធន៍<br>-អាចយកទៅអនុវត្តន៍បាន | ៣.១៩០ | - ស.ន.ព.ក.ប<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០២០ | ៦/២០២២ | |
| | ផ្សព្វផ្សាយជ្រើសរើសក្រុមយុវជន និងប្រជាពលរដ្ឋចូល ជាសមាជិកសហគមន៍នេសាទព្រែកក្របៅ | | ១.២០០ | | ២០២០ | ២០២១ | |
| | វគ្គបណ្តុះបណ្តាលស្តីពី ៖<br>-ការរៀបចំលិខិតរដ្ឋបាល របាយការណ៍ កំណត់ហេតុ<br>-គម្រោងស្នើសុំនិងការគ្រប់គ្រងថវិកា<br>-ការប្រើប្រាស់កំព្យូទ័រ<br>-ការគ្រប់គ្រងនិងសារៈសំខាន់នៃធនធានធម្មជាតិ<br>-សិទ្ធិជាមូលដ្ឋានលើធនធានធម្មជាតិ<br>-យេនឌ័រនិងការវិភាគយេនឌ័រ<br>-វិធីសាស្ត្រប្រមូលព័ត៌មាន<br>-ការប្រែប្រួលអាកាសធាតុ<br>-ការរៀបចំផែនការអាជីវកម្ម | | ៤.៦៧៥ | | ២០២០ | ៦/២០២២ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | -សម្របសម្រួលនិងដោះស្រាយទំនាស់ | | | | | | |
| គ៨.ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍ | វគ្គបណ្តុះបណ្តាលស្តីពីៈ<br>-បច្ចេកទេសចិញ្ចឹម(ត្រី កង្កែប អន្ទង់)<br>-បច្ចេកទេសកែច្នៃផល និងផលិតផលនេសាទ<br>-បច្ចេកទេសដាំបន្លែ<br>-បច្ចេកទេសកសិកម្មចម្រុះនិងបន្ត<br>--ជំនាញវិជ្ជាជីវៈលើការផ្តល់សេវាកម្សាន្ត<br>-ទស្សនៈកិច្ចសិក្សា | -មានចំណេះដឹងនិងបច្ចេកទេសលើមុខរបរ<br>-អាចអនុវត្តន៍បានក្នុងការប្រកបមុខរបរ<br>-បន្ថែមប្រាក់ចំណូលដើម្បីលើកកម្ពស់កម្រិតជីវភាព | ៨.៣០០ | - ស.ន.ព.ក.ប<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០២០ | ៦/២០២២ | |
| | បង្កើតក្រុមមុខរបរ ៖<br>-ក្រុមកែច្នៃផលនេសាទ<br>-ក្រុមដាំបន្លែ<br>-ក្រុមកសិកម្មចម្រុះ និងបន្ត | -មានក្រុមមុខរបរកើតឡើង<br>-មានផលិតផលផ្គត់ផ្គង់ទីផ្សារ<br>-លើកស្ទួយកម្រិតជីវភាព | ១.៨០០ | | | | |
| គ៩.ផែនការបង្កើតសហគមន៍នេសាទ ទេសចរណ៍ធម្មជាតិ | -ផ្សព្វផ្សាយឱ្យបានទូលំទូលាយ<br>-ទស្សនៈកិច្ចសិក្សា<br>-រៀបចំទីតាំងទេសចរណ៍ធម្មជាតិ<br>-បង្កើតក្រុមមុខរបរ<br>-ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងនៃក្រុម<br>-សន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យ | -ប្រភពចំណូលដល់សហគមន៍នេសាទ<br>-បង្កើតមុខរបរដល់សមាជិកសហគមន៍នេសាទ<br>-មានភ្ញៀវមកកម្សាន្ត | ១៨.៧៣៥ | - ស.ន.ព.ក.ប<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ៧/២០១៩ | ៦/២០២២ | |
| គ១០.ផែនការបង្កើតក្រុមឥណទាន(សន្សំប្រាក់)ដើម្បីបង្កើនមុខរបរ | -ផ្សព្វផ្សាយជ្រើសរើសអ្នកស្ម័គ្រចិត្តបង្កើតក្រុមឥណទាន(សន្សំប្រាក់)<br>-រៀបចំរចនាសម្ព័ន្ធនៃក្រុមឥណទាន<br>-ប្រជុំរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង<br>-ផ្តល់ទុនឥណទាននិងប្រមូលប្រាក់សន្សំ<br>ប្រជុំប្រចាំខែនិងរបាយការណ៍ឥណទាន | -មានក្រុមឥណទាន(សន្សំប្រាក់)<br>-មានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមឥណទាន<br>-មានដំណើរការល្អ(ខ្ចី សង)<br>-របាយការណ៍ឥណទាន<br>-ការរីកចម្រើននូវមុខរបរ | ៣.៧៧០ | - ស.ន.ព.ក.ប<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ៧/២០១៩ | ៦/២០២២ | |
| គ១១.ផែនការអភិវឌ្ឍន៍វារី | -ចិញ្ចឹមកង្កែប អន្ទង់តាមអាង ឬគង់ | -បង្កើតមុខរបរដល់សមាជិក | ២.៦០០ | - ស.ន.ព.ក.ប | ២០២០ | ៦/២០២២ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| វប្បកម្មក្នុងសហគមន៍នេសាទ | -ទិញពូជអន្ទង់ និងកង្កែប | សហគមន៍នេសាទ<br>-មានទិន្នផលកង្កែប អន្ទង់ផ្គត់ផ្គង់ទីផ្សារ<br>-លើកស្ទួយកម្រិតជីវភាព | | - រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | | | |
| គ១២.ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទព្រែកក្របៅ | -ប្រជុំជាមួយអ្នកពាក់ព័ន្ធ<br>-សាងសង់ស្នាក់ការ<br>-រៀបចំបណ្តាញអគ្គីសនី<br>-ទិញសម្ភារ | -ទទួលបានការចូលរួម ការគាំទ្រ<br>-សហគមន៍នេសាទមានការិយាល័យសម្រាប់ធ្វើការ<br>-មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រងកន្លែងនេសាទសហគមន៍<br>-មានថាមពលអគ្គីសនីសម្រាប់ស.នធ្វើការងារ<br>-មានសម្ភារប្រើប្រាស់<br>-សម្រេចបានសកម្មភាពការងារ | ១០.២៥០ | - ស.ន.ព.ក.ប<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០២០ | ២០២១ | |
| គ១៣.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ | -ប្រមូលភាគទានសមាជិកភាព<br>- ភាគទានប្រចាំឆ្នាំ<br>- ភាគទានពីអ្នកមិនមែនសមាជិក<br>សរសេរគម្រោងស្នើសុំពី ៖ ស្ថាប័នពាក់ព័ន្ធ (មន្ទីរជុំវិញខេត្ត) អង្គការដៃគូនានា និងសប្បុរសជន | មានថវិកាអនុវត្តន៍សកម្មភាពគ្រប់គ្រងសហគមន៍នេសាទ | ១៤១.១១៤ | - រាជរដ្ឋាភិបាល<br>- អង្គការដៃគូនានា<br>- សប្បុរសជន | ៧/២០១៩ | ៦/២០២២ | សរសេរគម្រោងចំណាយ ៥០០ |

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | ២០២១ | | | ២០២២ | | | | | |
| | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
| គ១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ២.ផែនការកែលម្អកន្លែងនេសាទសហគមន៍ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ៥.ផែនការទប់ស្កាត់បទល្មើសជលផល | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ៦.ផែនការប្រជុំប្រចាំខែនិងទិញសម្ភារការិយាល័យ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ៧.ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល | | | | | | | → | → | → | → | → | → | → | → | → | → | → | → |
| គ៨.ផែនការបង្កើតមុខរបរសមាជិកសហគមន៍នេសាទ | | | | | | | → | → | → | → | → | → | → | → | → | → | → | → |
| គ៩.ផែនការបង្កើតសហគមន៍នេសាទទេសចរណ៍ធម្មជាតិ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ១០.ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ១១.ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍ | | | | | | | → | → | → | → | → | → | → | → | → | → | → | → |
| គ១២.ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ | | | | | | | → | → | → | → | → | → | | | | | | |
| គ១៣.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |

បានឃើញនិងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលស្ទឹងស្លូត
"ដើម្បីជូនពិនិត្យនិងសម្រួល"
ថ្ងៃ....................ខែ.............ឆ្នាំ.......ឯកស័ក ព.ស ២៥៦
...............ថ្ងៃទី...០៥.........ខែ...០៦.....ឆ្នាំ២០១៩
៥.នាយសង្កាត់រដ្ឋបាលជលផលពាមជរ

លេខ......./១៩........
បានឃើញនិងគោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលពាមជរ
«ដើម្បីជូនពិនិត្យនិងសម្រួល»
ថ្ងៃ..........................ខែ..........ឆ្នាំ.......ឯកស័ក ព.ស២៥៦
ព្រែកក្របៅ ថ្ងៃទី......២៤.......ខែ...០៥...ឆ្នាំ២០១៩
មេឃុំព្រែកក្របៅ

សូមគោរពជូន
លោកមេឃុំព្រែកក្របៅ
«ដើម្បីជូនពិនិត្យនិងសម្រួល»
ថ្ងៃ..........................ខែ..........ឆ្នាំ.......ឯកស័ក ព.ស ២៥៦
ព្រែកក្របៅ ថ្ងៃទី.....២៤........ខែ...០៥... ឆ្នាំ២០១៩
ប្រធានគណៈកម្មការសហគមន៍នេសាទព្រែកក្របៅ

លេខ ០៧/១៩............
បានឃើញនិងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលព្រៃវែង
«ដើម្បីជូនពិនិត្យនិងសម្រួល»
ថ្ងៃ......ខែ......ឆ្នាំ......ឯកស័ក ព.ស ២៥៦៣
...............ថ្ងៃទី ០៦......ខែ......ឆ្នាំ២០១៩
នាយផ្នែករដ្ឋបាលជលផលស្ទឹងស្លូត

លេខ ២៤៥ ខណ្ឌ ៧៩
បានឃើញនិងគោរពជូន
លោកប្រធាន
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង
«ដើម្បីជូនពិនិត្យនិងសម្រួល»
ថ្ងៃ......ខែ......ឆ្នាំ......ឯកស័ក ព.ស ២៥៦៣
ព្រៃវែង ថ្ងៃទី ២៥......ខែ......ឆ្នាំ២០១៩
នាយខណ្ឌរដ្ឋបាលជលផលព្រៃវែង

**អ៊ូន សុណាត**

លេខ......
បានឃើញនិងគោរពជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
«ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ»
ថ្ងៃ......ខែ......ឆ្នាំ......ឯកស័ក ព.ស ២៥៦៣
ព្រៃវែង ថ្ងៃទី ២៥......ខែ......ឆ្នាំ២០១៩
ប្រធាន
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង

**អ៊ឹុក សំណាង**

លេខ......ជជ
បានឃើញនិងឯកភាព
ថ្ងៃ......ខែ......ឆ្នាំ......ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី......២៧......ខែ......ឆ្នាំ២០១៩
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារផ្សេងៗ

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ ព្រែកក្របៅ |
| ភូមិ | ៖ ឧត្តម ឧត្តុង្គ និងព្រែកក្របៅ |
| ឃុំ | ៖ ព្រែកក្របៅ |
| ស្រុក | ៖ ពាមជរ |
| ខេត្ត | ៖ ព្រៃវែង |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ខេត្តព្រៃវែង
ខណ្ឌរដ្ឋបាលជលផលព្រៃវែង
លេខ...២៤៣.../១៩... ខជ.ពវ

**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**តាមរយៈ** ៖ លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង។

**កម្មវត្ថុ** ៖ សំណើសុំចុះហត្ថលេខាលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ចំនួន៣ នៅខេត្តព្រៃវែង រួមមានសហគមន៍នេសាទស្វាយភ្លោះ សហគមន៍នេសាទព្រែកក្របៅ និងសហគមន៍នេសាទ អង្គរអង្គ ។

**យោង** ៖- អនុក្រឹត្យ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។
- ប្រកាសនេខ ៣១៦ ក្រក.កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ។
- អនុក្រឹត្យ៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១២ ស្តីពីការរំសាយឡូត៍នេសាទក្នុងខេត្តកណ្តាល កំពង់ចាម ព្រៃវែង និងតាកែវ និងរៀបចំជាកន្លែងអភិរក្សជលផល។

**ជូនភ្ជាប់**
- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ស្វាយភ្លោះ ចំនួន០១ច្បាប់
- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ព្រែកក្របៅ ចំនួន០១ច្បាប់
- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អង្គរអង្គ ចំនួន០១ច្បាប់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ យោង និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **ឯកឧត្តម ប្រតិភូ** មេត្តាជ្រាបថា ចាប់តាំងពីរាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់វិស័យជលផលមក ខណ្ឌរដ្ឋបាលជលផលព្រៃវែង បានខិតខំជំរុញដំណើរការរៀបចំសហគមន៍នេសាទនៅទូទាំងខេត្តបានយ៉ាងទូលំទូលាយ ដោយមានការចូលរួមយ៉ាងផុសផុលពីសំណាក់ប្រជាពលរដ្ឋ ដោយមានការគាំទ្រ និងសហការយ៉ាងល្អពីអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងមានការជួយឧបត្ថម្ភពីអង្គការនានា ។ ដំណើរការរៀបចំសហគមន៍នៅក្នុងខេត្តព្រៃវែង ទទួលបាននូវលទ្ធផលល្អគួរជាទីមោទនជាពិសេសបានរៀបចំសហគមន៍នេសាទបានចំនួន ២៨ សហគមន៍ និងបានកសាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ស្វាយភ្លោះ ព្រែកក្របៅ និងសហគមន៍អង្គរអង្គ សម្រាប់គ្រប់គ្រងជាបន្តទៀត ។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រតិភូ** មេត្តាពិនិត្យ និងចុះហត្ថលេខាដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រតិភូ** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ថ្ងៃច័ន្ទ ៧ រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ព្រៃវែង, ថ្ងៃទី...២៤... ខែមិថុនា ឆ្នាំ២០១៩
**នាយខណ្ឌរដ្ឋបាលជលផលព្រៃវែង**

អុន សុផលារិទ្ធ

លេខ...[illegible]... កសក.ពវ
បានឃើញ និងបញ្ជូនមក
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផលមេត្តាពិនិត្យ សម្រេចដោយអនុគ្រោះ។
ថ្ងៃ...[illegible]... ខែខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ព្រៃវែង, ថ្ងៃទី.................ខែមិថុនា ឆ្នាំ២០១៩
**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត**

ទិត សំណាង